អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៣

# សេចក្តីប្រកាសព័ត៌មាន

## លោក ប៉ិត ស៊ាងលីម និង លោក សូ មូស្សេទ្ធី ត្រូវបានចាត់តាំងជាមេធាវីការពារក្តី ដើម្បីតំណាងជនសង្ស័យពីររូបក្នុងសំណុំរឿង ០០៤

អង្គភាពគាំពារការការពារក្តីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) បានចាត់តាំងលោក ប៉ិត ស៊ាងលីម និង លោក សូ មូស្សេទ្ធី ជាសហមេធាវីជាតិ តំណាងជនសង្ស័យពីររូបផ្សេងគ្នា ដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ដោយសហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ទៅកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេត កាលពីថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ២០០៩។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី គឺជាផ្នែកនៃសំណុំរឿង ០០៤ ។

អត្តសញ្ញាណនៃជនសង្ស័យណាមួយ ដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី នៅតែរក្សាជាការសម្ងាត់ដដែល។

លោក ប៉ិត ស៊ាងលីម ជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាតាំងពីឆ្នាំ ១៩៩៧។ លោក ប៉ិត ស៊ាងលីម បញ្ចប់ការសិក្សានៅសាកលវិទ្យាល័យ Golden Gate និង សាកលវិទ្យាល័យ San Francisco នៅសហរដ្ឋអាមេរិក។ លោក ប៉ិត ស៊ាងលីម មានចំណេះដឹងជ្រៅជ្រះផ្នែកច្បាប់ និងនិតីព្រហ្មទណ្ឌកម្ពុជា។

លោក សូ មូស្សេទ្ធី បានចូលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាក្នុងខែធ្នូ ឆ្នាំ២០០៣ និងបានក្លាយជាសមាជិកពេញសិទ្ធិនៅខែមីនា ឆ្នាំ២០០៥។ ចាប់តាំងពីខែធ្នូ ឆ្នាំ ២០០៧ រហូតដល់ខែ មីនា ឆ្នាំ២០១៣ គាត់ធ្វើជាមន្ត្រីគ្រប់គ្រងសំណុំរឿងក្នុងក្រុមមេធាវីការពារក្តី អៀង សារី ក្នុងសំណុំរឿង ០០២ នៅ អ.វ.ត.ក។ ចាប់តាំងពីខែកញ្ញា ឆ្នាំ ២០១៣ គាត់ធ្វើជាមន្ត្រីគ្រប់គ្រងសំណុំរឿងក្នុងក្រុមមេធាវីការពារក្តីរបស់ជនសង្ស័យម្នាក់ក្នុងសំណុំរឿង ០០៣។ លោក សូ មូស្សេទ្ធី ជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យមួយនៅរាជធានីភ្នំពេញ។

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Porsenchey, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

ការចាត់តាំងនេះ ត្រូវបានធ្វើឡើងជាបឋម ដោយរង់ចាំការពិនិត្យជាក់ស្តែងលើការអះអាងអំពីភាពក្រីក្រ របស់ជនសង្ស័យ និង ការបំពេញបង្គ្រប់នូវរាល់ទម្រង់បែបបទផ្នែករដ្ឋបាលផ្សេងៗទៀត រួមទាំងការចាត់តាំងសហមេធាវីអន្តរជាតិផងដែរ។ អង្គភាពគាំពារការការពារក្តី បានពិចារណាដោយផ្អែកលើការចង់បានរបស់ជនសង្ស័យ និង បានពិនិត្យរាល់ការលះបង់សិទ្ធិទាំងអស់ពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍ មុននឹងធ្វើការចាត់តាំងនេះ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖


លោក Lars Olsen
មន្ត្រីទំនាក់ទំនងកិច្ចការច្បាប់
ទូរស័ព្ទ: +855 (0)12 488 023
Land line: +855 (0)23 861 669
Email: olsenl@un.org

លោក នេត្រ ភក្ត្រា
មន្ត្រីទទួលបន្ទុកសារព័ត៌មាន
ទូរស័ព្ទ: +855 (0)12 488 156
Land line: +855 (0)23 861 564
Email: neth.pheaktra@eccc.gov.kh